ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ជលផលកម្ពុជា (ដោយសង្ខេប)







ការបោះពុម្ពសៀវភៅនេះ ធ្វើឡើងក្រោមជំនួយរបស់សហភាពអឺរ៉ុប

# ជលផលកម្ពុជា
## (ដោយសង្ខេប)

ខ្លឹមសារនៅក្នុងសៀវភៅនេះជាការទទួលខុសត្រូវរបស់រដ្ឋបាលជលផលនិង
មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។

ឆ្នាំ២០១៤

រដ្ឋបាលជលផល

អាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ ៥៨២

## អារម្ភកថា

ស្រូវនិងត្រីជាអាហារប្រចាំថ្ងៃយ៉ាងសំខាន់របស់ប្រជាពលរដ្ឋខ្មែរតាំងពីសម័យបុរាណមក ហើយត្រីមានសារៈសំខាន់ខ្លាំងណាស់មិនអាចកាត់ថ្លៃនិងពិព័ណ៌នាបានឡើយ។ ម៉្យាងវិញទៀត ប្រទេសកម្ពុជាសម្បូរទៅដោយធនធានធម្មជាតិគ្រប់ប្រភេទ ជាពិសេសធនធានជលផលដោយសារទីតាំងភូមិសាស្ត្រអំណោយផលគឺមានប្រព័ន្ធទន្លេមេគង្គជាង៥០០គីឡូម៉ែត្រនិងបឹងទន្លេសាបដែលជាបេះដូងនៃប្រទេស។

វិស័យជលផលបានរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់ការងារដល់ប្រជាពលរដ្ឋប្រមាណ៦លាននាក់ ទាំងអ្នកធ្វើការពេញម៉ោងនិងមិនពេញម៉ោង បង្កើនជីវភាពរស់នៅ ផ្តល់នូវសន្តិសុខស្បៀងនិងបង្កើនផលិតផលក្នុងស្រុកប្រមាណ៨-១២% ដោយផលិតផលជលផលមានតម្លៃប្រមាណ១.៥០០លានដុល្លារសហរដ្ឋអាមេរិកក្នុង១ឆ្នាំ។

សព្វថ្ងៃនេះ ប្រទេសកម្ពុជាមានត្រីទឹកសាបប្រមាណ៥០០ប្រភេទនិងត្រីសមុទ្រ៥២០ប្រភេទ ហើយបរិមាណផលនេសាទសរុបប្រចាំឆ្នាំប្រមាណ៧០០-៨០០ពាន់តោនដែលជាប់ចំណាត់ថ្នាក់លេខ៤លើសកលលោក បន្ទាប់ពីប្រទេសចិន ឥណ្ឌា និងបង់ក្លាដែស។ ក្នុងនោះត្រីទឹកសាបប្រមាណ៥០០-៦០០ពាន់តោន សមុទ្រ១០០-១៥០ពាន់តោន និងវារីវប្បកម្ម៩០-១០០ពាន់តោន។ ដូចនេះ ប្រជាពលរដ្ឋខ្មែរម្នាក់គិតជាមធ្យមបរិភោគត្រី៦៣គីឡូក្រាមក្នុង១ឆ្នាំនិងទទួលបានប្រូតេអ៊ីនសាច់ពីត្រីចំនួន៨១,៥ %។

នាពេលបច្ចុប្បនេះ ប្រជាពលរដ្ឋមានការកើនឡើង ការប្រែប្រួលអាកាសធាតុ ការនេសាទហួសកម្រិត។ល។បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើធនធានមច្ឆជាតិ ទើបរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានធ្វើកំណែទម្រង់លើវិស័យជលផល ដោយលុបឡូត៍នេសាទទាំងអស់ទុកជូនប្រជាពលរដ្ឋគ្រប់គ្រង និងប្រើប្រាស់ប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រនិងទុកមួយផ្នែកជាកន្លែងអភិរក្ស។

ចាប់តាំងពីកំណែទម្រង់គោលនយោបាយវិស័យជលផលពី២០០០ដល់២០១៤ គឺអស់រយៈពេល១៤ ឆ្នាំកន្លងមកហើយ រដ្ឋបាលជលផលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការអនុវត្តតាមគោលនយោបាយកែទម្រង់ស៊ីជម្រៅនេះ រហូតសម្រេចបានជោគជ័យនិងទទួលបានសមិទ្ធផលយ៉ាងត្រចះត្រចង់ក្នុងនោះសមិទ្ធផលសំខាន់ៗរួមមានការអភិវឌ្ឍវារីវប្បកម្ម ការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍នេសាទ ការអភិរក្សធនធានជលផល ការកែលម្អនិងកំណត់ព្រំប្រទល់កន្លែងអភិរក្ស ការការពារព្រៃលិចទឹកនិងព្រៃកោងកាង ការអភិវឌ្ឍស្រះជម្រកត្រីសហគមន៍ ការកែច្នៃផលនេសាទនិងគុណភាព ការរៀបចំផែនការ ការសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយ។

សាស្ត្រាចារ្យបណ្ឌិត **ណៅ ធួក**

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

# មាតិកា

ទស្សនវិស័យសម្រាប់រដ្ឋបាលជលផល.........-២-
បេសកកម្មវិស័យជលផល.........-២-
អាណត្តិនៃរដ្ឋបាលជលផល.........-២-
កំណែទម្រង់វិស័យជលផល(២០០០-២០១២).........-២-
បរិមាណផលនេសាទពីឆ្នាំ(២០០០-២០១៣).........-៣-
ការអភិវឌ្ឍវារីវប្បកម្មនិងស្រះជម្រកត្រីសហគមន៍.........-៤-
ការគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍នេសាទ.........-៥-
សកម្មភាពអភិរក្សជលផល.........-៧-
សកម្មភាពអនុវត្តច្បាប់.........-៩-
ការកែលម្អដែននេសាទនិងការការពារព្រៃលិចទឹក.........-១១-
សកម្មភាពការងារនិងសមិទ្ធផលផ្នែកកែច្នៃជលផល.........-១២-
ការសិក្សាស្រាវជ្រាវ.........-១៣-
វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប.........-១៣-
មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍវារីវប្បកម្មសមុទ្រ.........-១៤-
មជ្ឈមណ្ឌលផលិតត្រីពូជបាទី .........-១៥-
វិទ្យាស្ថានជាតិស្រាវជ្រាវនិងអភិវឌ្ឍន៍វារីវប្បកម្មសម្តេចតេជោ ហ៊ុន សែន.....-១៥-
កិច្ចសហប្រតិបត្តិជាមួយកម្មវិធីនិងគម្រោងនានា.........-១៥-
ការបោះពុម្ពផ្សព្វផ្សាយ.........-១៧-
រចនាសម្ព័ន្ធរបស់រដ្ឋបាលជលផល.........-១៨-
សន្និដ្ឋាន.........-១៩-

ម.ឯ.ក AIDOC
Code: 147-033
Date:
Donated by:

## ទស្សនវិស័យសម្រាប់រដ្ឋបាលជលផល

គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកធានាសន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចម្រើននៃសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍប្រទេសជាតិ។

## បេសកកម្មវិស័យជលផល

- អភិរក្សធនធានជលផលនិងជីវចម្រុះប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកធានាសន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចម្រើននៃសេដ្ឋកិច្ចសង្គមនិងការអភិវឌ្ឍប្រទេសជាតិ
- ធានាការគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព
- អភិវឌ្ឍវារីវប្បកម្មដើម្បីរួមចំណែកធានាសន្តិសុខស្បៀងនិងកាត់បន្ថយភាពក្រីក្រ
- ធានាគុណភាពនិងសុវត្ថិភាពផលផលិតផលជលផលនិង
- អភិវឌ្ឍនិងគ្រប់គ្រងខ្សែចង្វាក់ផលិតកម្មផលនិងផលិតផលជលផល។

## អាណត្តិនៃរដ្ឋបាលជលផល

- ការងាររដ្ឋបាលរួមមាន ការគ្រប់គ្រងរដ្ឋបាល ការចាត់ចែងរាល់សកម្មភាពជលផល និងអភិវឌ្ឍន៍សហគមន៍នេសាទ
- ការងារបច្ចេកទេសរួមមាន ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ អភិរក្ស អភិវឌ្ឍន៍ សេដ្ឋកិច្ច បច្ចេកវិទ្យាជលផល និងបច្ចេកវិទ្យាដែលពាក់ព័ន្ធនឹងជលផល ព្រមទាំងការបង្កើនវារីវប្បកម្មនិង
- ការងារអនុវត្តច្បាប់រួមមាន ការងារអធិការកិច្ច ការអង្កេត ការតាមដាន និងការត្រួតពិនិត្យរាល់សកម្មភាពជលផលក្នុងតួនាទីជាមន្ត្រីនគរបាលយុត្តិធម៌។

## កំណែទម្រង់វិស័យជលផល(២០០០-២០១២)

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០១៤-២០១៨ និងក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩លើកស្ទួយផលិតផលជលផលដើម្បីបម្រើឲ្យការប្រើប្រាស់ក្នុងស្រុក និងទីផ្សារនាំចេញតាមរយៈ៖

- ការនេសាទត្រីធម្មជាតិទាំងសមុទ្រនិងទឹកសាប
- វារីវប្បកម្មសមុទ្រនិងទឹកសាប
- សម្របសម្រួលការកែច្នៃនិងការធ្វើពាណិជ្ជកម្ម។

តាំងពីឆ្នាំ២០០០ដល់២០១២ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់ស៊ីជម្រៅវិស័យជលផលដោយលុបឡូត៍នេសាទទាំងអស់ទុកជូនប្រជាពលរដ្ឋនេសាទលក្ខណៈគ្រួសារនិងកន្លែងអភិរក្សដែលមានដូចតារាងខាងក្រោម៖

| | ចំនួនឡូត៍ | ក្រឡាផ្ទៃ(ហ.ត) | ភាគរយ |
|---|---|---|---|
| កំណែទម្រង់លើកទី១(២០០០-២០១០) | ៧៨ | ៥៤១.២០៦ | ៥៦,៧៤ |
| កំណែទម្រង់លើកទី២(២០១២) | ៨០ | ៤១២.៥៣៤ | ៤៣,២៦ |
| កន្លែងអភិរក្ស | ៥០ | ៩៧.៥០៣ | ១០,២៣ |

បច្ចុប្បន្ននេះនៅព្រះរាជាណាចក្រកម្ពុជា ក្រៅពីឡូត៍នេសាទ នៅមានដាយត្រី ដាយបង្កង និងដាយត្រីលេញចំនួនទាំងអស់៩២ដាយ ក្នុងនោះដាយត្រីចំនួន៧១ដាយ ដាយបង្កងចំនួន១៣ដាយ និងដាយត្រីលេញចំនួន០៨ដាយ។ នៅរាជធានីភ្នំពេញមានដាយត្រីចំនួន២២ ដាយ ខេត្តកណ្តាលមានដាយត្រីចំនួន៤៩ដាយ និងដាយត្រីលេញចំនួន០១ដាយ ហើយខេត្តព្រៃវែងមានដាយបង្កងចំនួន១៣ដាយ និងដាយត្រីលេញចំនួន០៧ដាយ។

រាជរដ្ឋាភិបាលរក្សាទុកដាយត្រីទាំងអស់នេះសម្រាប់ផ្គត់ផ្គង់ត្រីប្រហុក ផ្អកដល់ប្រជាពលរដ្ឋ នៅក្នុងតំបន់ឬបណ្តាខេត្តជិតឆ្ងាយ ពីព្រោះវាជាអាហារមិនអាចខ្វះបានរបស់ប្រជាពលរដ្ឋខ្មែរ។ ដាយទាំងអស់នេះត្រូវបានដាក់ដេញថ្លៃជាសាធារណៈរៀងរាល់០២ឆ្នាំម្តង។





## បរិមាណផលនេសាទពីឆ្នាំ(២០០០-២០១៣)




នៅក្នុងរយៈពេល១៤ឆ្នាំនេះ បរិមាណផលនេសាទសរុបមានការកើនឡើង ហើយក្នុងនោះ បរិមាណផលនេសាទទឹកសាបខ្ពស់ជាងបរិមាណផលនេសាទសមុទ្រ តែមានការប្រែប្រួលតិចតួច និងមានការអភិវឌ្ឍវារីវប្បកម្មកើនឡើង។ ប្រជាពលរដ្ឋខ្មែរម្នាក់ៗគិតជាមធ្យមបរិភោគត្រី៦៣ គីឡូក្រាមក្នុងមួយឆ្នាំ ក្នុងនោះប្រភេទត្រីទឹកសាប៤៤,២ គីឡូក្រាម ប្រភេទត្រីទឹកសមុទ្រ១៧,៣ គីឡូក្រាម និងប្រភេទត្រីចិញ្ចឹម១,៣គីឡូក្រាម ហើយទទួលបានប្រូតេអ៊ីនសាច់ពីត្រីរហូតដល់៨១,៥ ភាគរយ។ ជាបរិមាណត្រីកែច្នៃជាក់ស្តែង ប្រជាពលរដ្ឋខ្មែរម្នាក់បរិភោគប្រហុក៥,២គីឡូក្រាម ផ្អកឬមាំ៤,៨គីឡូក្រាម ត្រីឆ្អើរ៨,៣ គីឡូក្រាម ត្រីងៀត៩,៣ គីឡូក្រាម និងទឹកត្រី៤,៥ លីត្រ។





## ការអភិវឌ្ឍវារីវប្បកម្មនិងស្រះជម្រកត្រីសហគមន៍

នៅពេលបច្ចុប្បន្ននេះ ប្រជាពលរដ្ឋខ្មែរមានការយល់ដឹងនិងផ្លាស់ប្ដូរទម្លាប់ពីការពឹងផ្អែកលើត្រីនៅក្នុងបឹងធម្មជាតិមកការចិញ្ចឹមត្រីវិញ ដូចនេះការចិញ្ចឹមត្រីមានការរីកចម្រើនផុលផុសគួរឲ្យកត់សម្គាល់ ក្នុងនោះបរិមាណផលិតកូនត្រីពូជ ចំនួនកសិដ្ឋានផលិតកូនត្រីពូជ ចំនួនសហគមន៍ស្រះជម្រកត្រីមានការកើនឡើងពី១ឆ្នាំទៅ១ឆ្នាំ។

ស្រះជម្រកត្រីជាប្រភេទតំបន់ការពារឬអភិរក្សត្រី ជាទូទៅត្រូវបានបង្កើតឡើងនៅតាមតំបន់ទំនាបវាលស្រែដែលលិចទឹកនៅរដូវវស្សា ឆ្ងាយពីតំបន់មជ្ឈដ្ឋានទឹកធម្មជាតិដែលមានទឹកពេញមួយរដូវ។ សារៈប្រយោជន៍នៃស្រះជម្រកត្រី គឺចូលរួមចំណែកដ៏ធំធេងក្នុងការបង្កើនធនធានជលផល និងផលនេសាទនៅតាមតំបន់ទំនាបវាលស្រែ។ បច្ចុប្បន្ន ស្រះជម្រកត្រីត្រូវបានបង្កើតបានចំនួនសរុប៨២០កន្លែងដែលផែនការបន្តទៀតនិងរៀបចំឲ្យបានយ៉ាងតិច១ស្រះក្នុង១ឃុំទូទាំងប្រទេស។




ប្រជាពលរដ្ឋប្រមាណ៦៣.០០០គ្រួសារបានចូលរួមនៅក្នុងសកម្មភាពចិញ្ចឹមត្រីដែលបានទទួលការបណ្ដុះបណ្ដាលបច្ចេកទេសពីរដ្ឋបាលជលផល ក្នុងនោះមានកសិករ១៥៤នាក់ជាគ្រូបង្គោលនិងជាគ្រូផ្សព្វផ្សាយនៅតាមមូលដ្ឋាន។ ប្រភេទត្រីចិញ្ចឹមរួមមាន ត្រីស្លត់ ត្រី-តុកកែ ក្រែងឈាម ត្រីឆ្ពិន ត្រី កាហែ ត្រីប្រាថំ ត្រីក្រាញ់ ត្រីអណ្ដែងកូនកាត់ ត្រីខ្យា ត្រីព្រលូង ត្រីកន្ធរ ត្រីទីឡាព្យ៉ា ត្រីកាបស ត្រីកាបសាមញ្ញ អន្ទង់ និងបង្កងទៀតផង។ នាពេលបច្ចុប្បន្ននេះ បរិមាណផលវារីវប្បកម្មមានចំនួន៩០. ០០០តោន ស្មើ១២%នៃបរិមាណផលត្រីសរុបដែលក្នុងនោះមានវារីវប្បកម្មទឹកសាប៩០% និងសមុទ្រ១០%។

| ចំនួនកន្លែងភ្ញាស់ត្រីនិងស្រះជម្រកត្រីសហគមន៍(ឆ្នាំ២០០០ទៅដល់ឆ្នាំ២០១៣) | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក. | ៥ | ៦ | ១៤ | ៣៦ | ៤៨ | ៦៣ | ៦៩ | ៨៣ | ១៤៥ | ១៩៥ | ២៧៣ | ២៨០ | ២៩៦ | ៣០៧ |
| ខ. | ២ | ៣ | ៨ | ១៥ | ២២ | ២៩ | ៣៦ | ៤៩ | ១៦៣ | ៣១៧ | ៦៥៤ | ៧៣៨ | ៧៦៤ | ៨២០ |
| | ក.ចំនួនកសិដ្ឋានផលិតកូនត្រីពូជ | | | | | ខ.ចំនួនសហគមន៍ស្រះជម្រកត្រី | | | | | | | | |

សមិទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានៈ

១. បានរៀបចំបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងដំណើរការរៀបចំនិងគ្រប់គ្រងសហគមន៍នេសាទ។

២. រៀបចំសហគមន៍នេសាទបានចំនួន៥១៦សហគមន៍ ដែលមានសមាជិកសរុបចំនួន៣៣២.១៦៨នាក់ (ប្រមាណជាង៣៥% ជាស្ត្រី) ត្រូវជា១៤៧.៥១៨ គ្រួសារ ក្នុងនោះសហគមន៍នេសាទដែលមានទីតាំងនៅក្នុងដែននេសាទទឹកសាបមានចំនួន៤៧៧និងតំបន់ឆ្នេរមានចំនួន៣៩សហគមន៍។ សហគមន៍នេសាទចំនួន៣៧០ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ចំពោះសហគមន៍នេសាទនៅសល់ផ្សេងទៀត រដ្ឋបាលជលផលកំពុងរៀបចំឯកសារពាក់ព័ន្ធ ដើម្បីបញ្ជូនទៅក្រសួកងសិកម្ម រុក្ខាប្រមាញ់ និងនេសាទសុំចុះបញ្ជីជាបន្តបន្ទាប់ទៀត។

៣. បើកវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាបានចំនួន៨២៨វគ្គ ដែលមានអ្នកចូលរួមចំនួន២៥.៦២២នាក់ (ប្រមាណជាង៤០%ជាស្ត្រី)។

៤. ផ្សព្វផ្សាយបានចំនួន៧៦៩ វគ្គ ដែលមានអ្នកចូលរួមចំនួន១០៩.៩៤១នាក់ (ប្រមាណជាង ៥០% ជាស្ត្រី)។

៥. រៀបចំទស្សនកិច្ចសិក្សាបានចំនួន៧៥លើក ដែលមានអ្នកចូលរួមចំនួន១.៦៧២នាក់ (ប្រមាណជាង៣៥%ជាស្ត្រី)។

៦. បោះបង្គោលព្រំប្រទល់កន្លែងនេសាទសហគមន៍បានចំនួន៥.៦៣៣ និងស្លាកសញ្ញាចំនួន ៤២៦ស្លាក។

៧. រៀបចំធនាគារក្តាមបានចំនួន៣២កន្លែងស្មើនឹង៩៥ បៃ ដែលបានលែងមេក្តាមចូលចំនួន ៣៥.៧៦៣គីឡូក្រាមស្មើនឹង២៥៩.៤៩៨ក្បាល ដែលបានបញ្ចេញកូនក្តាមប្រមាណ ៣៦៦ ពាន់លានក្បាលទៅក្នុងដែននេសាទវិញ ហើយផលក្តាមបានកើនឡើងចំនួន៤ដង។

៨. អនុវត្តជម្រើសមុខរបរចិញ្ចឹមជីវិតដោយសហគមន៍នេសាទរួមមាន ការធ្វើអាងភ្ញាស់ ការចិញ្ចឹមត្រី ការដាក់របាំងផ្ទស់ចាប់ត្រី ដាយត្រី ការចិញ្ចឹមជន្លេន ការដាំបន្លែ និងបណ្តុះផ្សិត ការកែច្នៃផលនេសាទដែលមានស្ត្រីចូលរួមយ៉ាងសកម្ម។ ជាមួយគ្នានេះ សហគមន៍នេសាទបានទទួលកម្មវិធីឥណទានខ្នាតតូចពីគម្រោងជួយខ្លួនឯង(ទុនសន្សំពីសមាជិក)សប្បុរសជននិងអង្គការនានាផងដែរ។ បច្ចុប្បន្ននេះ សហគមន៍នេសាទមួយចំនួនមានប្រាក់សន្សំ